# ១០-ប្រកាសស្តីពីការកែសម្រួល និងការបង្កើតបន្ថែម គណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យ អនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៤៨ សហវ

# ប្រកាស
## ស្តីពី
## ការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា នៃប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា៦នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៤៨ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការបង្កើត និងការប្រព្រឹត្តទៅនៃមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលគណនី និងអនុគណនី ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចខាងក្រោម÷

១.អនុគណនីលេខ ៦១០៩១ ដែលមានខ្លឹមសារពន្យល់ "ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យា ដែលជ្រើសរើសដោយក្រសួង ស្ថាប័នផ្ទាល់" ទៅជា "ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យា ដែលជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់"។

២.អនុគណនីលេខ ៦១០៩៣ ដែលមានខ្លឹមសារពន្យល់ "ចំណាយលើបុគ្គលិក-សហម្ភូហភាពផ្សេងទៀត ដែលមិនមែនជាមន្ត្រីរាជការ ដូចជា÷ ចំណាយលើប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ និងបុគ្គលិកឃុំ ដែលដឹកក្មេងៗទៅសាលា, សហគមន៍, ភូមិ, ឃុំ ។ល។" ទៅជា "ចំណាយលើបុគ្គលិក-សហម្ភូហភាពផ្សេងទៀត ដែលមិនមែនជាមន្ត្រីរាជការ ដូចជា÷ ចំណាយលើប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ និងបុគ្គលិកឃុំ ដែលដឹកក្មេងៗ ទៅសាលា, សហគមន៍, ភូមិ, ឃុំ, ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ, ជំនួយការលើការងាររសោភាសង្គមរដ្ឋបាល, ម្ដាយបង្គោល, និងអ្នកពាក់ព័ន្ធផ្សេងទៀត"។

៣.គណនីលេខ ៦២០១ ដែលមានឈ្មោះ "អត្ថប្រយោជន៍សន្តិសុខសង្គម" ទៅជា "អត្ថប្រយោជន៍របបសន្តិសុខសង្គម" និងខ្លឹមសារពន្យល់ "ជាអត្ថប្រយោជន៍ហិរញ្ញវត្ថុ ដែលបានទទួលដោយកម្មករ ដែលបានចូលនិវត្តន៍ ដែលបានបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធសន្តិសុខសង្គម ក្នុងអំឡុងពេលធ្វើការរបស់គេ" ទៅជា "ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់របបសន្តិសុខសង្គមរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បុគ្គលិក កម្មករ និងនិយោជិត"។

៤.អនុគណនីលេខ ៦២០១១ ដែលមានឈ្មោះ "អត្ថប្រយោជន៍សន្តិសុខសង្គម" ទៅជា "ភាគទានសម្រាប់របបសន្តិសុខសង្គម" និងខ្លឹមសារពន្យល់ "ជាអត្ថប្រយោជន៍ហិរញ្ញវត្ថុ ដែលបានទទួលដោយកម្មករ ដែលបានចូលនិវត្តន៍ ដែលបានបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធសន្តិសុខសង្គម ក្នុងអំឡុងពេលធ្វើការរបស់គេ" ទៅជា "ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការបង់ភាគទាន សម្រាប់របបសន្តិសុខសង្គមរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បុគ្គលិក កម្មករ និងនិយោជិត"។

៥.អនុគណនីលេខ ៧៨០៣២ ដែលមានខ្លឹមសារពន្យល់ "ចំណូលពីការលក់ទ្រព្យសម្បត្តិរឹបអូសពីការបង្ក្រាបបទល្មើសគ្រឿងញៀន" ទៅជា "ចំណូលពីការលក់ទ្រព្យសម្បត្តិរឹបអូសពីការបង្ក្រាបបទល្មើសគ្រឿងញៀន និង/ឬ បទល្មើសផ្សេងៗទៀត"។

**ប្រការ២.-**

ត្រូវបានបង្កើតបន្ថែមគណនី និងអនុគណនីក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ដូចខាងក្រោម÷

១.អនុគណនីលេខ ៦២០១២ "ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០១"អត្ថប្រយោជន៍របបសន្តិសុខសង្គម" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

២.អនុគណនីលេខ ៦២០១៣ "ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០១"អត្ថប្រយោជន៍របបសន្តិសុខសង្គម" នៃជំពូក ៦២"អត្ថប្រយោជន៍សង្គម"។

៣.អនុគណនីលេខ ៦២០១៤"ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០១ "អត្ថប្រយោជន៍របបសន្តិសុខសង្គម" នៃជំពូក ៦២"អត្ថប្រយោជន៍សង្គម"។

៤.អនុគណនីលេខ ៦២០១៨"អត្ថប្រយោជន៍របបសន្តិសុខសង្គមផ្សេងៗ" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០១ "អត្ថប្រយោជន៍របបសន្តិសុខសង្គម" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

៥.គណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" ដែលស្ថិតនៅក្នុងជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

៦.អនុគណនីលេខ ៦២០៧១ "ឧបត្ថម្ភលើការថែទាំសុខភាព" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

៧.អនុគណនីលេខ ៦២០៧២"ឧបត្ថម្ភមាតុភាព" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧"ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

៨.អនុគណនីលេខ ៦២០៧៣"ឧបត្ថម្ភមរណភាព" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧"ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២"អត្ថប្រយោជន៍សង្គម"។

៩.អនុគណនីលេខ ៦២០៧៤"ឧបត្ថម្ភនិវត្តជន" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧"ឧបត្ថម្ភលើ តាវកាលិក" នៃជំពូក ៦២"អត្ថប្រយោជន៍សង្គម"។

១០.អនុគណនីលេខ ៦២០៧៥ "ឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬ សមត្ថភាពការងារ" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

១១.អនុគណនីលេខ ៦២០៧៦ "ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

១២.អនុគណនីលេខ ៦២០៧៧ "ឧបត្ថម្ភគ្រោះថ្នាក់ការងារ និងទពលភាព" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

១៣.អនុគណនីលេខ ៦២០៧៨ "ឧបត្ថម្ភតាវកាលិកផ្សេងៗ" ដែលស្ថិតនៅក្នុងគណនីលេខ ៦២០៧ "ឧបត្ថម្ភលើតាវកាលិក" នៃជំពូក ៦២ "អត្ថប្រយោជន៍សង្គម"។

១៤.អនុគណនីលេខ ៧៥០១៥ "ឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់តាវកាលិក" ដែលស្ថិតនៅក្នុងគណនីលេខ ៧៥០១ "ឧបត្ថម្ភធនពីថ្នាក់ជាតិ" នៃជំពូក ៧៥ "ការឧបត្ថម្ភ និងអំណោយ"។

១៥.គណនីលេខ ៧៥២០ "ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ" ដែលស្ថិតនៅក្នុងជំពូក ៧៥ "ការឧបត្ថម្ភ និងអំណោយ"។

១៦.អនុគណនីលេខ ៧៥២០១ "ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត" ដែលស្ថិតនៅក្នុងគណនីលេខ ៧៥២០ "ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ" នៃជំពូក ៧៥ "ការឧបត្ថម្ភ និងអំណោយ"។

១៧.អនុគណនីលេខ ៧៥២០២ "ឧបត្ថម្ភធនពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ" ដែលស្ថិតនៅក្នុងគណនីលេខ ៧៥២០ "ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ" នៃជំពូក ៧៥ "ការឧបត្ថម្ភ និងអំណោយ"។

១៨.អនុគណនីលេខ ៧៥២០៣ "ឧបត្ថម្ភធនពីមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ" ដែលស្ថិតនៅក្នុងគណនីលេខ ៧៥២០ "ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ" នៃជំពូក ៧៥ "ការឧបត្ថម្ភ និងអំណោយ"។

១៩.គណនីលេខ ៧៧០៦ "ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម" ដែលស្ថិតនៅក្នុងជំពូក ៧៧ "ផលផ្សេងៗ និងផលពិសេស"។

២០.អនុគណនីលេខ ៧៧០៦១ "ភាគទានបានទទួល សម្រាប់ហានិភ័យការងារ" ដែលស្ថិតនៅក្នុងគណនីលេខ ៧៧០៦ "ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម" នៃជំពូក ៧៧ "ផលផ្សេងៗ និងផលពិសេស"។

២១.អនុគណនីលេខ ៧៧០៦២ "ភាគទានបានទទួល សម្រាប់ធានារ៉ាប់រងសុខភាព" ដែលស្ថិតនៅក្នុងគណនីលេខ ៧៧០៦ "ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម" នៃជំពូក ៧៧ "ផលផ្សេងៗ និងផលពិសេស"។

២២.អនុគណនីលេខ ៧៧០៦៣ "ភាគទានបានទទួល សម្រាប់សោធន" ដែលស្ថិតនៅក្នុងគណនីលេខ ៧៧០៦ "ភាគទាន បានទទួល សម្រាប់របបសន្តិសុខសង្គម" នៃជំពូក ៧៧ "ផលផ្សេងៗ និងផលពិសេស"។

**ប្រការ៣.-**

សេចក្តីពន្យល់ពីមាតិកាថវិកានៃគណនី និងអនុគណនី ដែលត្រូវបានកែសម្រួល ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤.-**

អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចរៀបចំបង្កើតបន្ថែម ឬ កែសម្រួលមាតិកាថវិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ច តាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំ ហើយនៅចុងឆ្នាំនីមួយៗត្រូវរៀបចំប្រកាស

បំពេញបន្ថែម ឬ កែសម្រួលមាតិកាថវិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ចនោះ ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងចុះហត្ថលេខា។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវបានទុកជានិរាករណ៍។

**ប្រការ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល ៖</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ឯកសារ-កាលប្បវត្តិ

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់មាតិកាថវិកា |
|---|---|---|---|---|
| 61 | | | សោធារកម្ម | |
| | 6109 | | បុគ្គលិកខាងក្រៅ | |
| | | 61091 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | ចំណាយលើការផ្តល់ទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យាដែលជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់។ |
| | | 61093 | បុគ្គលិកសម្ពហភាពសាធារណៈផ្សេងៗ | ចំណាយលើបុគ្គលិក-សហម្ពហភាពផ្សេងទៀត ដែលមិនមែនជាមន្ត្រីរាជការ ដូចជា÷ ចំណាយលើប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍ និងបុគ្គលិកឃុំ ដែលយកក្មេងៗទៅសាលា, សហគមន៍, ភូមិ, ឃុំ, ភ្នាក់ងារទ្រទ្រង់សុខភាពភូមិ, ជំនួយការលើការងារសេវាសង្គមរដ្ឋបាល, ម្តាយបង្គោល, និងអ្នកពាក់ព័ន្ធផ្សេង ទៀត។ |
| 62 | | | អត្ថប្រយោជន៍សង្គម | |
| | 6201 | | អត្ថប្រយោជន៍របបសន្តិសុខសង្គម | ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់របបសន្តិសុខសង្គមរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បុគ្គលិក កម្មករ និងនិយោជិត។ |
| | | 62011 | ភាគទានសម្រាប់របបសន្តិសុខសង្គម | ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បុគ្គលិក កម្មករ និងនិយោជិត។ |
| | | 62012 | ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | ចំណាយដែលបានផ្តល់ឧបត្ថម្ភធនដល់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ដើម្បីបើកផ្តល់តាវកាលិក។ |
| | | 62013 | ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន | ចំណាយដែលបានឧបត្ថម្ភធនដល់បេឡាជាតិអតីតយុទ្ធជន សម្រាប់បើកផ្តល់តាវកាលិក។ |

| | | | | |
|---|---|---|---|---|
| | | 62014 | ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម | ចំណាយដែលបានឧបត្ថម្ភធនដល់បេឡាជាតិរបបសន្តិសុខ [illegible] តាវកាលិក។ |
| | | 62018 | អត្ថប្រយោជន៍របបសន្តិសុខសង្គមផ្សេងៗ | ចំណាយអត្ថប្រយោជន៍សន្តិសុខសង្គមសម្រាប់អង្គភាពផ្សេងៗ ក្រៅពីអនុគណនី [illegible] ខាងលើ។ |
| | 6207 | | ឧបត្ថម្ភលើតាវកាលិក | ជាចំណាយរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម លើការបើកផ្តល់តាវកាលិករបស់និវត្តជន និងរបស់កម្មករ និយោជិត។ |
| | | 62071 | ឧបត្ថម្ភលើការថែទាំសុខភាព | ចំណាយលើការខូចខាតសេវាពិនិត្យសុខភាព ព្យាបាលជំងឺ ថែទាំវេជ្ជសាស្ត្រ និងឧបត្ថម្ភប្រាក់កម្រៃប្រចាំថ្ងៃ។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ដែលទទួលបាននេះសម្រាប់តែកម្មករ និងនិយោជិតក្នុងវិស័យឯកជន។ |
| | | 62072 | ឧបត្ថម្ភមាតុភាព | ចំណាយឧបត្ថម្ភជូនកម្មការិនី និងនិយោជិត ដែលបានឈប់សម្រាកសម្រាលកូននៅមូលដ្ឋានសុខាភិបាល និងចំណាយឧបត្ថម្ភបន្ថែមនៅពេលសម្រាលកូន។ |
| | | 62073 | ឧបត្ថម្ភមរណភាព | ចំណាយឧបត្ថម្ភជារបបចុងក្រោយម្តងគត់ នៅពេលទទួលមរណភាពរបស់អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន កម្មករ និងនិយោជិត។ |
| | | 62074 | ឧបត្ថម្ភនិវត្តជន | ចំណាយលើសោធនប្រចាំខែសម្រាប់និវត្តជន ដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន កម្មករ និងនិយោជិតដែលបានបំពេញតាមលក្ខខណ្ឌកំណត់(អតីតភាពការងារ និងអាយុចូលនិវត្តន៍) ដោយមិនគិតរបបរបស់អ្នកនៅក្នុងបន្ទុកចូលទេ។ |
| | | 62075 | ឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬ សមត្ថភាពការងារ | ចំណាយលើសោធនប្រចាំខែសម្រាប់ជនបាត់បង់សម្បទា វិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន កម្មករ និងនិយោជិត ដែលបានបំពេញតាមលក្ខខណ្ឌកំណត់(អតីតភាពការងារ និងបាត់បង់សម្បទាវិជ្ជាជីវៈពុំអាចបម្រើការងារបន្តទៀតបាន)។ |

| | | | | |
|---|---|---|---|---|
| | | 62076 | ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក | -ចំណាយឧបត្ថម្ភប្រចាំខែជូនសហព័ទ្ធ កូន ឪពុក ម្តាយ [illegible] របស់អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។<br>-ចំណាយឧបត្ថម្ភប្រចាំខែជូនសហព័ទ្ធ កូន ឪពុក ម្តាយ និង[illegible] អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល កម្មករ និងនិយោជិត ដែល[illegible] |
| | | 62077 | ឧបត្ថម្ភគ្រោះថ្នាក់ការងារ និងពិការភាព | ចំណាយឧបត្ថម្ភប្រចាំខែជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និងនិយោជិត ដែលទទួលគ្រោះថ្នាក់ក្នុងពេលបំពេញការងារ ឬ បេសកកម្ម។ |
| | | 62078 | ឧបត្ថម្ភការកាលិកផ្សេងៗ | ចំណាយលើការកាលិកផ្សេងទៀតក្រៅពីការកាលិកខាងលើ ដូចជា៖ ឧបត្ថម្ភបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ។ល។ |
| 74 | | | ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | កត់ត្រាចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្មដែលត្រូវបង់ទៅរដ្ឋ ចំពោះបទល្មើសនឹងច្បាប់ ឬ បទបញ្ញត្តិរដ្ឋបាល។ ការពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធដែលទាក់ទងនឹងពន្ធពិសេសមួយ ត្រូវបានចុះជាចំណូលក្នុងផ្នែកនេះ ប៉ុន្តែការផាកពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធផ្សេងៗទៀត ត្រូវបានកត់ត្រានៅក្នុងចំណូលសារពើពន្ធផ្សេងៗទៀត។ រួមទាំងការពិន័យផ្សេងទៀតដែលជាចំណូលមិនមែនសារពើពន្ធ។ |
| | 7403 | | ចំណូលពីការរឹបអូស | ចំណូលទទួលបានពីការរឹបអូសប្រាក់កក់ និងទ្រព្យសម្បត្តិចំពោះការមិនអនុវត្តតាមលក្ខខណ្ឌកិច្ចសន្យា។ |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | ចំណូលពីការលក់ទ្រព្យសម្បត្តិរឹបអូសពីការបង្ក្រាបបទល្មើសគ្រឿងញៀន និង/ឬ បទល្មើសផ្សេងៗទៀត។ |
| 75 | | | ការឧបត្ថម្ភ និងអំណោយ | ការឧបត្ថម្ភ ឬ អំណោយអាចជាហិរញ្ញវត្ថុ ឬ សម្ភារ។ |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | ចំណូលដែលបានទទួលការឧបត្ថម្ភពីថ្នាក់ជាតិ។ |
| | | 75015 | ឧបត្ថម្ភពីក្រសួង ស្ថាប័ន សម្រាប់ការកាលិក | ចំណូលរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម ដែលបានទទួលពីក្រសួង ស្ថាប័ន សម្រាប់បើកផ្តល់ការកាលិក។ |

| | | | | |
|---|---|---|---|---|
| | 7520 | | ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ | ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានទទួលពីមូលនិធិរបស់រដ្ឋបាលថ្នាក់ជាតិ ឬ ពីមូល[illegible]។ |
| | | 75201 | ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត | ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានទទួល[illegible]របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 75202 | ឧបត្ថម្ភធនពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានទទួលពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 75203 | ឧបត្ថម្ភធនពីមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ | ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលបានទទួលពីមូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ។ |
| 77 | | | ផលផ្សេងៗ និងផលពិសេស | |
| | 7706 | | ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម | ចំណូលរបស់បេឡាជាតិសន្តិសុខសង្គម ដែលបានពីការបង់ភាគទានរបស់ក្រសួង ស្ថាប័ន របស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អតីតមន្ត្រីរាជការ អតីតយុទ្ធជន កម្មករ និយោជិត និងនិយោជក សម្រាប់បើកផ្តល់តាវកាលិក។ |
| | | 77061 | ភាគទានបានទទួល សម្រាប់ហានិភ័យការងារ | ចំណូលរបស់បេឡាជាតិសន្តិសុខសង្គម ដែលបានពីការបង់ភាគទានរបស់និយោជក សម្រាប់ហានិភ័យការងារ។ |
| | | 77062 | ភាគទានបានទទួល សម្រាប់ធានារ៉ាប់រងសុខភាព | ចំណូលរបស់បេឡាជាតិសន្តិសុខសង្គម ដែលបានពីការបង់ភាគទានរបស់ក្រសួង ស្ថាប័ន របស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អតីតមន្ត្រីរាជការ អតីតយុទ្ធជន កម្មករ និយោជិត និងនិយោជក សម្រាប់ធានារ៉ាប់រងសុខភាព។ |
| | | 77063 | ភាគទានបានទទួល សម្រាប់សោធន | ចំណូលរបស់បេឡាជាតិសន្តិសុខសង្គម ដែលបានពីការបង់ភាគទានរបស់ក្រសួង ស្ថាប័ន របស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អតីតមន្ត្រីរាជការ អតីតយុទ្ធជន កម្មករ និយោជិត និងនិយោជក សម្រាប់សោធន។ |